STREAM

ឆ្នាំទី១ លេខ១ ខែមករា-មីនា ២០០២

**Support to Regional Aquatic Resources Management**

**គំរោងជួយគ្រប់គ្រងធនធានវារីជាតក្នុងតំបន់**

# ទស្សនាវដ្តី STREAM

**ការទំនាក់ទំនង និង ការរៀនសូត្រពីជីវភាពរស់នៅរបស់អ្នកនេសាទ និង កសិករ**

គំរោងត្រូវបានការជួយឧបត្ថម្ភដោយ AusAID, DFID, FAO, NACA និង VSO

# មាតិកា


| អត្ថបទ | ទំព័រ |
| --- | --- |
| រៀនសូត្រអំពីជំលោះពីគ្នាទៅវិញទៅមក<br>Ronet Santos | ១ |
| ការរៀនសូត្រតាមរយៈ **Internet (e-learning)** ដើម្បីជួយរំលែកនូវចំណេះដឹងខាងផ្នែកធនធានវារិជាត<br>Robert T Raab និង Jonathan Woods | ៤ |
| យុទ្ធសាស្ត្រការចិញ្ចឹមជីវិត យិនឌឺ និង ការចូលរួមក្នុងវារីវប្បកម្ម : លទ្ធផលបានមកពីការស្រាវជ្រាវដោយមានការចូលរួម នៅភាគពាយ័ព្យនៃប្រទេសស៊ីរីលង្កា<br>Lindsay J Pollock និង David C Little | ៨ |
| ធ្វើអន្តរកម្មជាមួយអ្នកជាប់ពាក់ព័ន្ធ និង អ្នកធ្វើគោលនយោបាយ<br>To Phuc Tuong | ១២ |
| តួនាទីនៃចំណេះដឹងខាងជីវជាតិក្នុងការជួយសំរួលបញ្ហាលំបាកនៅក្នុងតំបន់អាស៊ីប៉ាស៊ីភិច<br>Georgina Cairns | ១៥ |
| ពតិមានពីទស្សនាវដ្តីរបស់ **STREAM** | ១៩ |
| ពតិមានពី **STREAM** | ២១ |

**កំណត់ចំណាំ** :

ការរៀនសូត្រ ការគ្រប់គ្រងជំលោះ បច្ចេកវិទ្យាពត៌មាន និង ទំនាក់ទំនង ការគ្រប់គ្រងធនធានវារិជាត ច្បាប់ ការចិញ្ចឹមជីវិត យិនឌឺ ការចូលរួម អ្នកជាប់ពាក់ពន្ធ័ គោលនយោបាយ និង ការទំនាក់ទំនង គឺជាគោលសំខាន់ៗដែលមាននៅក្នុងអត្ថបទទាំង ៦ នៅក្នុងទស្សនាវដ្ដីលើកដំបូងនេះ ។ ទស្សនាវដ្ដីនេះបានលើកឡើងនូវរឿងរ៉ាវជាច្រើនដែល STREAM ចង់ចែករំលែកនូវការរៀនសូត្រ និង បង្កើនទំនាក់ទំនងរវាងគ្នា។ ទស្សនាវដ្ដីរបស់ STREAM នឹងលើកឡើងផងដែរនូវបញ្ហា និង បរិបទដែលបានមកពីទស្សនះផ្សេងៗ ហើយបានចងក្រងនូវឯកសារទាំងនេះ ។ គោលបំណងគឺមិនមែនរិះគន់ទេ ប៉ុន្តែចូលរួមជាមួយសហការីផ្ដល់ជាគំនិតក្នុងន័យស្ថាបនា។

ទស្សនាវដ្ដីនឹងរីកចំរើនហើយ និង ផ្លាស់ប្ដូរនៅពេលដែលយើងបានយល់ដឹង និង ប្រើវាឱ្យជាឧបករណ៍ផ្ដល់ពត៌មាន និង មានប្រយោជន៍ដល់អ្នកអាន ។ យើងបាននិយាយគ្នាហើយថា អត្ថបទទាំងអស់ត្រូវសរសេរជាភាសាអង់គ្លេសដែលងាយយល់ដើម្បីឱ្យអ្នកអានគ្រប់ប្រភេទអាចយល់ ( អ្នកខ្លះអាចឆ្លៀតឱកាសនេះដើម្បីបង្កើនចំណេះដឹងខាងភាសាអង់គ្លេសរបស់ពួកគេ ) ហើយអត្ថបទទាំងនេះក៏ងាយស្រួលក្នុងការបកប្រែទៅជាភាសាជាតិ ហើយចែកចាយដោយមណ្ឌលទំនាក់ទំនងពត៌មានរបស់ STREAM នៅក្នុងប្រទេសរៀងៗខ្លួន។

លេខទី១ នៃទស្សនាវដ្ដីរបស់ STREAM ក្នុងនោះអត្ថបទ២នឹងផ្ដោតទៅលើ " ចំណេះដឹងនៅក្នុងដៃអ្នកប្រើប្រាស់ "។ បន្ទាប់មកអត្ថបទ៣នឹងផ្ដោតទៅលើបញ្ហានៃការចូលរួម : ក្នុងការស្រាវជ្រាវដោយមានការចូលរួមពីកសិករ (In farmer-managed research trials) ក្នុងគោលនយោបាយ និង ច្បាប់របស់រដ្ឋាភិបាល និង ក្នុងរចនាសម្ព័ន្ធអនុវត្ត។ អត្ថបទចុងក្រោយនឹងផ្ដោតទៅលើ " ទំនាក់ទំនង " ដែលជាផ្នែកមួយនៃ STREAM ក្នុងការលើកកំពស់រៀនសូត្រ និង ទំនាក់ទំនង ក្នុងនោះយើងពិនិត្យមើលលើគោលការណ៍នៃម្ហូបចំណីអាហារ និង ផ្នែកដែលទាក់ទង នឹងយើងទាំងអស់គ្នា។

ទស្សនាវដ្ដីរបស់ STREAM នឹងក្លាយទៅជាមធ្យោបាយមួយសំរាប់ភ្ជាប់ទំនាក់ទំនងជាមួយអ្នកអាន ។ ក្នុងនោះយើងចង់ឱ្យអ្នកអានចូលរួមនៅក្នុងការពិភាក្សាពីអត្ថបទរបស់ទស្សនាវដ្ដី STREAM នៅលើវេទិកាពិភាក្សានៃ Website របស់ STREAM: www.streaminitiative.com.org ។

សូមលោកអ្នកអានដោយក្ដីរីករាយ

លោក Graham Haylor នាយកគំរោង STREAM

លោក William Savage បណ្ណាធិការទស្សនាវដ្ដី STREAM

# រៀនសូត្រអំពីជំលោះ ពីគ្នាទៅវិញទៅមក

ដោយលោក Ronet Santos

## <u>ភូមិមួយ និង ក្រុមហ៊ុនមួយ</u> :

ប៊ីនយ៉ាមីន តាវ៉ាក់គឺជាប្រជាជនដែលរស់នៅភាគខាងកើតនៃកោះកាលីម៉ាន់តាន់ ប្រទេសឥណ្ឌូនេស៊ី ។ គាត់រស់នៅក្នុងព្រៃចំងាយប្រហែល ៣00 គីឡូម៉ែត្រពីទីក្រុងសាម៉ារីនដា ។ ជីវភាពរស់នៅរបស់គាត់ពឹងផ្អែកលើការដាំផ្កា ធ្វើស្រែ បរបាញ់សត្វ និង រកត្រីនៅតាមទន្លេ ។ ប៊ីនយ៉ាមីនគឺជាប្រធានសមាគមភូមិ គាត់បានប្រាប់យើងថា គាត់បានចំណាយពេលជាង ៤ ខែនៅក្នុងគុក។ គាត់បានដឹកនាំអ្នកភូមិទៅដុតជំរំនៃក្រុមហ៊ុនមួយដែលចង់បង្កើតកន្លែងដាំដុះដូងប្រេងមួយនៅលើដីជីដូនជីតារបស់ពួកគាត់នៅដាយ៉ាក់។ គាត់បាននិយាយថា ក្រុមហ៊ុនបានចុះកិច្ចព្រមព្រៀងជាមួយរដ្ឋាភិបាលប្រទេសឥណ្ឌូនេស៊ី ប៉ុន្តែគេមិនដែលពិគ្រោះយោបល់ជាមួយប្រជាជន ដាយ៉ាក់ពីបញ្ហានេះទេ ។ ក្រុមហ៊ុនបានបដិសេធមិនចរចារជាមួយអ្នកភូមិ ដូច្នេះពួកគេបង្ខំចិត្តត្រូវដុតជំរំរបស់ក្រុមហ៊ុន។

ភូមិរបស់ប៊ីនយ៉ាមីនមិនចង់ឱ្យក្រុមហ៊ុនមកបង្កើតកន្លែងដាំដុះដូងប្រេងទេ ។ ពួកគេគិតថាការដាំដុះដូងប្រេងនេះមិនបានផ្តល់ផលប្រយោជន៏ឱ្យដល់ពួកគេទេ ប៉ុន្តែថែមទាំងបំផ្លាញដល់ព្រៃឈើរបស់ពួកគេទៀត។ ក្រុមហ៊ុនបានប្រកែកថា ការដាំដុះនេះនឹងផ្តល់ផលប្រយោជន៏ល្អដល់សេដ្ឋកិច្ចជាតិឥណ្ឌូនេស៊ី ហើយចុងក្រោយគឺដល់ប្រជាជនដាយ៉ាក់នេះតែម្តង។ ប៊ីនយ៉ាមីនមានអារម្មណ៏ថា រដ្ឋបាលក្នុងស្រុក ប៉ូលីស និង ទាហានត្រូវដៃត្រូវជើងជាមួយនឹងក្រុមហ៊ុន។

## <u>សំណួរ និង ចំលើយ</u> :

ប៊ីនយ៉ាមីនត្រូវបានគេជ្រើសរើសជាអ្នកចូលរួមម្នាក់ក្នុងចំណោម ១១ នាក់ក្នុងនោះមានជនជាតិឥណ្ឌូនេស៊ី ៣ នាក់, ថៃ៣ នាក់ និង ហ្វីលីពីន ៤ នាក់ ។ នៅក្នុងទស្សនៈកិច្ចសិក្សារបស់គំរោង SPARK នៅប្រទេសហ្វីលីពីនក្នុងកំឡុងខែ សីហា និង កញ្ញា ឆ្នាំ ២០០១ គាត់បានទស្សនា និង ពិភាក្សាជាមួយសហគមន៏ពីបទពិសោធន៏របស់ពួកគេលើការគ្រប់គ្រងជំលោះ ។ គាត់មានចំណាប់អារម្មណ៏ចង់ដឹង ថាតើត្រូវចរចារជាមួយក្រុមដែលមានអំណាចយ៉ាងដូចម្តេច ដូចជាក្រុមហ៊ុនធំៗ ហើយត្រូវបង្រួបបង្រួមនូវភាពមិនចុះសម្រុងគ្នានៅក្នុងសហគមន៏យ៉ាងដូចម្តេច ?

ក្នុងកំឡុងពេលទស្សនៈកិច្ចសិក្សា អ្នកចូលរួមទាំងអស់បានឮនូវអ្នកឡើងធ្វើបទបង្ហាញម្នាក់គឺ មេធាវី អ៊ីប៉ាត់លូណា ដែលធ្វើការនៅមូលនិធិ Babilonia Wilner ដោយពិភាក្សាទៅលើការចរចារផ្អែកលើមូលដ្ឋានផលប្រយោជន៏ដែលផ្ទុយទៅនឹងការតថ្លៃគ្នា ។ ពួកគេក៏បានឮពីអ្នកធ្វើបទបង្ហាញផ្សេងៗទៀតដែលនិយាយពីសារៈសំខាន់នៃការមាន

" ការស្មើភាព " នៅក្នុងការចរចារពីជំលោះ ។ ប៊ីនយ៉ាមីនមានសំណួរជាច្រើន បើសិនជាសហគមន៍ប្រឆាំងទល់នឹងអ្នកមានអំណាច តើយើងអាចមានស្មើភាពគ្នាយ៉ាងដូចម្តេច? ហើយបើសិនជាសមាជិកសហគមន៍ណាម្នាក់ត្រូវបានជ្រើសរើសដោយក្រុមហ៊ុន តើយើងអាចបង្កើតនូវសាមគ្គីភាពនៅក្នុងសហគមន៍យ៉ាងដូចម្តេច?

ទស្សនកិច្ចសិក្សានេះ បានផ្តល់ឱកាសឱ្យប៊ីនយ៉ាមីនអាចឆ្លើយនូវសំណួរទាំងនេះ ។ គាត់មិនបានរៀនពីសៀវភៅ វគ្គបំពាក់បំប៉ន ឬក៏ពីអ្នកជំនាញណាម្នាក់ទេ ប៉ុន្តែគាត់រៀនពីសហគមន៍ផ្សេងទៀតដែលកំពុងជួបប្រទះស្ថានភាពជំលោះប្រហាក់ប្រហែលគ្នា ។ អ្នកដឹកនាំទស្សនកិច្ចសិក្សាបានប្រាប់គាត់ថា យើងត្រូវការច្បាប់បន្ថែមទៀតនៅហ្វីលីពីនដើម្បីឱ្យមានភាពស្មើគ្នា ។ យើងចាំបាច់ត្រូវធ្វើឱ្យមានការចាប់អារម្មណ៍ដល់ភាគីផ្សេងទៀតដែលថាសហគមន៍គឺមានការម៉ឺងម៉ាត់ និង ត្រូវបង្ខំពួកគេឱ្យចរចារ ហើយគិតគូរដល់សហគមន៍។

## <u>ស្វែងយល់ និង ធ្វើសកម្មភាព</u> :

តាមរយៈវិធានការវាយតំលៃជនបទដោយមានការចូលរួម (PRA) ដូចជា ផែនទីធនធាន រដូវកាល លំហាត់លំដាប់ថ្នាក់ លំហាត់ " សេចក្តីត្រូវការ និង ការខ្លាចក្រែង " និង ការវិភាគអ្នកជាប់ពាក់ព័ន្ធដែលបានធ្វើឡើងជាមួយសហគមន៍នៅ អាន់ដា ប៉ង់ហ្គាស៊ីណាន់ នៅប្រទេសហ្វីលីពីន ប៊ីនយ៉ាមីនបានលាក់យុទ្ធសាស្ត្រ និង ស្ថានភាពគ្រប់គ្រងជំលោះជាក់ស្តែង ។ យុទ្ធសាស្ត្រខ្លះទទួលបានជោគជ័យ ប៉ុន្តែខ្លះទៀតមិនទាន់បានជោគជ័យនៅឡើយ។ ប៉ុន្តែនៅក្នុងដំណើរការនេះ ប៊ីនយ៉ាមីនទទួលបាននូវការយល់ដឹងពីគោលការណ៍ និង ជំហានក្នុងការគ្រប់គ្រងជំលោះដែលមិនត្រូវការប្រើកំលាំងដើម្បីឈានទៅរកកិច្ចព្រមព្រៀង ។ គាត់បានរៀនពីប្រព័ន្ធគ្រប់គ្រងជំលោះដែលយកផលប្រយោជន៍របស់ប្រជាជនមកពិចារណា ។ ប៊ីនយ៉ាមីន ប្រហែលជាមិនអាចយកបទពិសោធន៍ពីសហគមន៍ផ្សេងទៀតយកទៅអនុវត្តនៅកន្លែងគាត់ដោយផ្ទាល់បានទេ ប៉ុន្តែវាបានផ្តល់ឱ្យគាត់នូវគំនិតដើម្បីវិភាគពីស្ថានភាពនៅសហគមន៍របស់គាត់ ។ នៅពេលដែលគាត់ត្រលប់ទៅផ្ទះវិញ គាត់មានបំណងចង់យកនូវបទពិសោធន៍ដែលគាត់បានរៀនមកធ្វើជាផែនការសកម្មភាព។

លោក Ronet Santos គឺជាអ្នកសំរបសំរួលកម្មវិធីក្នុងតំបន់របស់អង្គការ VSO-SPARK, Quezon city, Philippines ហើយអាចទំនាក់ទំនងតាមរយៈអ៊ីមែល Ronet.Santos@vsoint.org ។ បើចង់ដឹងច្បាស់ពីសហគមន៍របស់ប៊ីនយ៉ាមីនសូមទាក់ទង Lembaga Bina Benua (LBB) Puti Jalia ( Centre for Indigenous People Empowerment) តាមរយៈអ៊ីមែល benua@samarinda.org បើចង់ដឹងពតិមានបន្ថែមពី SPARK និង ទស្សនកិច្ចសិក្សា សូមទាក់ទងតាមរយៈអ៊ីមែល Jocel. Pangilinan@vsoint.org



អ្នកចូលរួមក្នុងទស្សនកិច្ចសិក្សារបស់ SPARK (ចែករំលែក និង លើកកំពស់ការយល់ដឹង និង ចំណេះដឹងក្នុងតំបន់) ជាមួយសហគមន៍ និង មន្ត្រីរដ្ឋាភិបាលក្នុងស្រុកបានគូរផែនទីធនធាន រដូវកាល និង ការប្រើប្រាស់ឧបករណ៍ដើម្បីពិភាក្សាពីជំលោះដែលទាក់ទងនឹងការគ្រប់គ្រងធនធានធម្មជាតិ ។

SPARK ចាប់ផ្តើមពីខែ មករា ឆ្នាំ ២000 (Sharing and Promotion of Awareness and Regional Knowledge) ជាកម្មវិធីដែលមានរយៈពេល ៥ ឆ្នាំដែលជំរុញឱ្យសហគមន៍រៀនពីគ្នាទៅវិញទៅមកពីយុទ្ធវិធីគ្រប់គ្រងដោយនិរន្តភាពក្នុងប្រទេសឥណ្ឌូនេស៊ុី, ហ្វីលីពីន និង ថៃ ។ កម្មវិធី SPARK មានផ្នែកជាច្រើនដែលរួមមានការជួយដល់សហគមន៍ និង អង្គការដែលមានស្រាប់ក្នុងការអនុវត្តន៍សកម្មភាពគ្រប់គ្រងធនធានធម្មជាតិតាមបែបសហគមន៍ ។ ក្នុងនោះមានភ្នាក់ងារអភិវឌ្ឍន៍ស្ម័គ្រចិត្តជំនួយតូច១ សិក្ខាសាលា និង សន្និសិទ ការស្រាវជ្រាវ ទស្សនកិច្ចសិក្សា អាហារូបករណ៏ ទស្សនាវដ្តី និង ពតិមានអ្នកដែលធ្វើការនៅក្នុងផ្នែក CBNRM ។ ការអនុវត្តន៏នៅក្នុងប្រទេសនិមួយ១គឺផ្អែកទៅលើបញ្ហារបស់ក្រុមប្រឹក្សានៃសមាជិកទាំង៤ របស់ CBNRM ក្នុងនោះ ២នាក់ជាអ្នកស្ម័គ្រចិត្តក្នុងស្រុក និង ២នាក់ទៀតជាអ្នកស្ម័គ្រចិត្ត VSO ។ SPARK ធ្វើការយ៉ាងជិតស្និទ្ធជាមួយអង្គការនៅក្នុងប្រទេសនិមួយ១ ដើម្បីធានាថា អត្ថប្រយោជន៏ដែលទទួលបានក្នុងរយៈពេល៥ ឆ្នាំ នឹងឋិតថេរនៅក្នុងបណ្តាញ SPARK នៃប្រទេសនិមួយ១ ។

# ការរៀនសូត្រតាមរយៈ Internet (e-learning) ដើម្បីជួយរំលែកនូវចំណេះដឹងខាងផ្នែកធនធានវារិជាត

ដោយលោក Robert T Raab និង Jonathan Woods

អ្នកអានទស្សនាវដ្តីរបស់ STREAM បានដឹងរួចមកហើយពីសារៈសំខាន់នៃធនធានវារិជាត និង បញ្ហាដែលត្រូវប្រឈមមុខក្នុងការគ្រប់គ្រងវាឱ្យមាននិរន្តរភាព ។ មានប្រជាជនប្រមាណ ១៥០ លាននាក់ទូទាំងពិភពលោកពឹងផ្អែកលើមុខរបរនេសាទ ។ ប្រជាជន ១ ពាន់លាននាក់ ពឹងផ្អែកលើផលត្រីដែលជាសេចក្តីត្រូវការប្រូតេអ៊ីនរបស់ពួកគេ ។ ការប្រើប្រាស់ទាំងនេះបានឈានទៅរកការវិនាសហិនហោចនៃផលស្តុកធម្មជាតិ ហើយការជំនួសមកវិញតាមរយៈការធ្វើវារីវប្បកម្មមិនមានកត្តាណាមួយបញ្ជាក់ថាមាននិរន្តរភាព ឬក៏អ្នកក្រីក្រមានលទ្ធភាពដែរ (ICLARM) ។

## ការទំនាក់ទំនងគឺជាគន្លឹះ :

មានមនុស្សជាច្រើនដែលធ្វើការនៅក្នុងវិស័យជលផលបានជឿថា ការប្រើប្រាស់ចំណេះដឹងសមស្របអាចលើកកំពស់និរន្តរភាព និងការរក បានជាពិសេសចំណេះដឹងដែលចាំបាច់ដើម្បីគ្រប់គ្រងធនធានវារិជាតឱ្យកាន់តែប្រសើរឡើង ។ ដូចលោក Degnbol (1998) បានបញ្ជាក់ថា ការស្រាវជ្រាវជលផលបានផ្តោតទៅលើបញ្ហាគ្រប់គ្រង និង " ការអភិវឌ្ឍន៍គឺផ្អែកទៅលើការគ្រប់គ្រងឱ្យកាន់តែប្រសើរឡើងលើធនធានធម្មជាតិដែលមាន ជៀសវាងការពង្រីកនូវការប្រើប្រាស់ធនធាន " Meryl Williams អគ្គនាយកនៃអង្គការ ICLARM បានបន្ថែមទៀតថា " ចំណេះដឹងអំពីអន្តរកម្មក្នុងប្រព័ន្ធធនធានវារិជាត ដែលរួមមាន ទឹកប្រៃ ទឹកសាប សមុទ្រ បឹង ទន្លេ និង ស្រះដាក់ទៅក្នុងដៃអ្នកប្រើប្រាស់ ដោយបង្កើតនូវបរិយាកាសសំរាប់ពិភាក្សាគ្នាថា តើត្រូវគ្រប់គ្រងធនធានវារិជាតឱ្យមាននិរន្តរភាពយ៉ាងដូចម្តេច? ជាពិសេសអ្វីដែលជះឥទ្ធិពលទៅលើអ្នកក្រីក្រ (ICLARM,2002) ។

## ការរៀនតាមរយៈ Internet (e-learning)

សិល្បៈនៃ "ការផ្តល់ចំណេះដឹងទៅក្នុងដៃអ្នកប្រើប្រាស់ " គឺកំពុងមានការរីកចំរើនយ៉ាងខ្លាំងដោយសារមានការទំនាក់ទំនង និង បច្ចេកវិទ្យាពតិមានថ្មីៗដែលធ្វើឱ្យអង្គការផ្សេងៗកាន់តែមានការងាយស្រួលក្នុងការចែករំលែកនូវចំណេះដឹងដល់អតិថិជនរបស់ខ្លួន ឧទា. វិធានទាំងនេះនឹងដើរតួនាទីសំខាន់ក្នុងវគ្គបំពាក់បំប៉នផ្លូវការ និង ការអប់រំបន្តសំរាប់អ្នកឯកទេសធនធានវារិជាត ។ ការប្រើប្រាស់ (e-learning) នៅក្នុងវិស័យអប់រំគឺជារឿងអស្ចារ្យមួយ ។ (e-learning) កើតឡើងនៅកន្លែងដែលគ្រូបង្រៀន និង សិស្សនៅឆ្ងាយពីគ្នា ដោយចំងាយ និង ពេលវេលា ឬអាច

ទាំងចំងាយពីរ ហើយឆ្លៀតយកផលប្រយោជន៍ពីបច្ចេកវិទ្យានៃបណ្តាញដើម្បីបង្កើត ជំរុញ ផ្តល់ និង សំរួលក្នុងការរៀនសូត្រនៅគ្រប់ពេល និង គ្រប់ទីកន្លែង។

ថ្វីត្បិតតែ STREAM មិនមានជំនាញនៅក្នុង (e-learning)តែ STREAM មានដៃគូជាមួយមជ្ឈមណ្ឌលបច្ចេកវិទ្យាអាស៊ីប៉ាស៊ីភិច (APRTC) ដើម្បីទទួលបាននូវសមត្ថភាពនេះ។ APRTC (Asia-Pacific Regional Technology Center) គឺជាអង្គការ (e-learning) ក្នុងតំបន់មួយដែលផ្តល់នូវជំនាញតាមរយៈ Internet និង មានសមត្ថភាពបច្ចេកទេសខ្ពស់ដែល STREAM អាចប្រើដើម្បីសំរេចនូវទិសដៅរបស់ខ្លួន ។

## <u>មជ្ឈមណ្ឌលបច្ចេកវិទ្យាអាស៊ីប៉ាស៊ីភិច</u> (APRTC)

APRTC គឺជាអង្គការមិនទទួលផលកំរៃក្នុងតំបន់មួយដើម្បីលើកកំពស់សុខមាលភាព កសិករ និង អ្នកនេសាទនៅតំបន់អាស៊ីប៉ាស៊ីភិច ។ វាត្រូវបានបង្កើតឡើងដើម្បីលើកកំពស់ការប្រើប្រាស់ធនធានធម្មជាតិឱ្យមាននិរន្តរភាព តាមរយៈការបង្កើនអ្នកប្រើប្រាស់រកបាននូវពត៌មាន និង ចំណេះដឹង ។ ថ្វីត្បិតតែពីមុនការរីកចំរើនខាងផ្នែកកសិកម្ម និង ជលផល បានជួយដល់ការកែលំអបែបបទបុរាណ APRTC ជឿថាការធ្វើឱ្យប្រសើរឡើងនៅពេលអនាគតគឺផ្អែកទៅលើការប្រើប្រាស់ពត៌មានទៅលើការគ្រប់គ្រងធនធាន ។ ការគ្រប់គ្រងចំណេះដឹងអាចលើកកំពស់ផលចំណេញ ផលិតកម្ម និង និរន្តរភាពក្នុងវិស័យកសិកម្ម និង ជលផល។

កម្មវិធី e-learning (ការរៀនសូត្រតាមរយៈInternet )ជាចំបងរបស់ APRTC គឺ agLe@rnដែលផ្តោតទៅលើការអប់រំបន្តនៃអ្នកឯកទេស ក្នុងវិស័យកសិកម្ម និង ជលផល ។ អ្នកទាំងអស់នេះអាចជួយដល់កសិករ និង អ្នកនេសាទឱ្យរកបាននូវពត៌មាន និង ចំណេះដឹងដែលគេត្រូវការដើម្បីគ្រប់គ្រងឱ្យកាន់តែប្រសើរ ។ អ្នកឯកទេសទាំងនេះត្រូវការនូវចំណេះដឹងដូចកសិករ និង អ្នកនេសាទដែរ ។ ពួកគេត្រូវការចាំបាច់នូវចំណេះដឹង និង ពត៌មានដែលថ្មីៗ និង ជាឱកាសដើម្បីបង្កើនជំនាញរបស់ពួកគេ ។ e-learning គឺសមស្របទៅនឹងការងារទាំងនេះ ប៉ុន្តែជំហានដំបូងពួកគេត្រូវរៀនពីមូលដ្ឋាននៃ ឌីជីថល (Digital)។

## <u>មូលដ្ឋាននៃឌីជីថល</u> (Digital literacy)

សមត្ថភាពដ៏សំខាន់ និង មូលដ្ឋានគ្រឹះសំរាប់ម្នាក់ៗដែលចង់ទាញយកផលប្រយោជន៍ពីពត៌មានដែលមាននៅលើ Internet និង ឱកាសរៀនសូត្រ គឺ មូលដ្ឋាននៃឌីជីថល " ជាលទ្ធភាពដែលអាចរកបាន និង ទាញយកផលប្រយោជន៍ ពី ធនធានដែលមាននៅលើបណ្តាញកំព្យូទ័រដើម្បីប្រើ និង ស្វែងយល់ពីពត៌មានដែលមាននៅកំព្យូទ័រ "។ ដោយមានជំនាញជាមូលដ្ឋានជាមួយផ្នែកទន់ (software)និង មានកំព្យូទ័រភ្ជាប់ Internet អ្នកអាច :

- ទំនាក់ទំនងជាមួយអ្នកផ្សេងទៀតមានតំលៃថោក
- រកបាននូវពតិមានដែលចេះតែកើនឡើងជាលំដាប់ទាំងពតិមានទូទៅ និង ពតិមានសំរាប់អ្នកឯកទេសដែលមាននៅលើបណ្តាញ Internet និង
- ទាញយកផលប្រយោជន៍ពីវគ្គបំពាក់បំប៉នផ្លូវការ និង មិនផ្លូវការដែលមាននៅលើ Internet ស្ទើរគ្រប់ទីកន្លែង

## សហប្រតិបត្តិការរវាង STREAM និង APRTC :

ការផ្តោតជាសំខាន់របស់ STREAMគឺ "រាល់មធ្យោបាយទំនាក់ទំនងនឹងត្រូវបានគេយកមកពិចារណាដើម្បីសំរេចបាននូវការចែកចាយយ៉ាងឆាប់រហ័ស និង ទូលំទូលាយ អាចទុកចិត្តបាន និង មានតំលៃថោក ។ ក្នុងនោះរួមមាន ការរកបាននូវពតិមានឌីជីថល និង ការប្រើប្រាស់ Internet ទូរស័ព្ទ ឯកសារ និង កិច្ចប្រជុំថ្នាក់ជាតិ និង ថ្នាក់តំបន់ " ។ STREAM នឹង " ជួយប្រមូល និង ចែកចាយនូវពតិមាន និង ពង្រឹងនូវសមត្ថភាពនៃបណ្តាញពតិមានដែលមានស្រាប់ និង បណ្តាញទំនាក់ទំនងផ្សេងៗទៀតក្នុងគោលបំណងចែករំលែកនូវចំណេះដឹង និង បទពិសោធន៍ ( Anonymous,2002 ) ។

ជាអកុសលដោយសារតែចំណេះដឹងផ្នែកមូលដ្ឋានឌីជីថលនៃអ្នកឯកទេសខាងការគ្រប់គ្រងធនធានវារិជាតក្នុងតំបន់នៅមានកំរិតទាប ធ្វើឱ្យរាំងរាំងដល់កិច្ចខិតខំប្រឹងប្រែងទាំងនេះ ។ បើសិនជាបុគ្គលិករបស់ STREAM មានចំណេះដឹងខាងមូលដ្ឋានឌីជីថលទាប ធ្វើឱ្យមានការរអាក់រអួលដល់ការអនុវត្តន៍គំរោង ។ គំរោង STREAM បានដោះស្រាយបញ្ហានេះដោយបានចុះឈ្មោះអ្នកគ្រប់គ្រងមណ្ឌលទំនាក់ទំនងរបស់ខ្លួនឱ្យរៀន " មូលដ្ឋានគ្រឹះឌីជីថលសំរាប់អ្នកឯកទេសកសិកម្ម " ។ ថ្មីៗនេះសហការីរបស់ STREAM ៣ នាក់មកពីកម្ពុជា ថៃ និង វៀតណាមបានរៀនវគ្គបំពាក់បំប៉នតាមរយៈ Internet រយៈពេល ៦ សប្តាហ៍ ។ ពួកគេស្ថិតនៅក្នុងចំណោមមនុស្ស ១៤ នាក់ផ្សេងទៀតដែលធ្វើការនៅក្នុងវិស័យកសិកម្មទូទាំងតំបន់អាស៊ីប៉ាស៊ីភិច ។

យើងសង្ឃឹមថានឹងអាចសរសេរអត្ថបទតាមដានដោយលំអិតពីបទពិសោធន៍ និង ប្រតិកម្មរបស់ពួកគេក្នុងការរៀបចំវគ្គបំពាក់បំប៉នស្តីពី "មូលដ្ឋានគ្រឹះរបស់ឌីជីថល" នៅពេលអនាគត ។ បើពិនិត្យឱ្យជ្រៅជាងនេះបន្តិចយើងអាចនិយាយបានថាការដាក់ឱ្យប្រើប្រាស់នូវបច្ចេកវិទ្យាថ្មីនេះអាចផ្តល់នូវពតិមាន និង ចំណេះដឹងដោយផ្ទាល់ទៅក្នុងដៃអ្នកប្រើប្រាស់ធនធានវារិជាតក្រីក្រ ។ មានកិច្ចខិតខំជាច្រើនបានបញ្ជាក់ថា បច្ចេកវិទ្យាពតិមាន និង

ទំនាក់ទំនងអាចត្រូវបានគេយកទៅប្រើប្រាស់ដើម្បីផ្តល់ពតិមានដល់សហគមន៍ក្រីក្រ (Fontaine and Fuchs, 2000) ។

## ឯកសារយោង


Anonymous 2002 STREAM: A New Conduit for Aquaculture. *New Agriculturalist Online*. www.new-agri.co.uk/02-1/development/dev01.html

Degnbol, P 1998 *Fisheries Research in Development.* Danish Institute for Fisheries Research. Keynote paper presented at the Conference on Fisheries Research in Developing Countries. The Research Council of Norway, Oslo, 21-22 October 1998. www.ifm.dk/reports/46.pdf

Fontaine, M and Fuchs, R 2000 The Watering Hole: Creating Learning Communities with Computers. *TechKnowLogia, May-June*. Knowledge Enterprise, Inc. www.ict.aed.org/infocenter/pdfs/thewatering.pdf

ICLARM 2002 www.iclarm.org/objgov.htm



*Robert T Raab is Director of APRTC, Bangkok, Thailand, and can be reached at* <robert@aprtc.org>. *Jonathan Woods is a Web Developer at APRTC and can be reached at* <woods_jonathan@hotmail.com>.


To learn more about APRTC and its “Digital Literacy” and other courses, please visit the APRTC Website at http://www.aprtc.org

# យុទ្ធសាស្ត្រការចិញ្ចឹមជីវិត យិនឌឺ និង ការចូលរួមក្នុងវារីវប្បកម្ម
# លទ្ធផលបានមកពីការស្រាវជ្រាវដោយមានការចូលរួម
# នៅភាគពាយ័ព្យនៃប្រទេសស៊ីរីលង្កា

ដោយលោក Lindsay J Pollock និង David C Little

## មូលដ្ឋានគ្រឹះ :

ខេត្តភាគពាយ័ព្យនៃប្រទេសស៊ីរីលង្កាគឺសំបូរទៅដោយអាងធារាសាស្ត្រ ។ អាងធារាសាស្ត្រដែលធំហើយចាស់គឺបានជួយដល់ជីវភាពរស់នៅរបស់កសិករជាច្រើនដែលតាំងទីលំនៅនៅទីនោះក្រោមគំរោងផ្សេងៗរបស់រដ្ឋាភិបាល ។ ឥឡូវនេះអាងទាំងនេះបានជួយដល់ជីវភាពរស់នៅរបស់អ្នកនេសាទ និង អ្នករកស៊ីលក់ត្រីជាច្រើន ដែលពឹងផ្អែកលើទិន្នផលត្រីទីឡាព្យ៉ា ។ ដោយមានការលេចឡើងនូវកសិករជំនាន់ថ្មី និង មានការកើនឡើងនូវតំលៃផលិតកម្មកសិកម្ម អ្នកតាំងទីលំនៅពីមុនៗ និង កូនចៅរបស់ពួកគេជាច្រើនបានធ្វើនេសាទជាមុខរបរបន្ទាប់បន្សំសំរាប់ចិញ្ចឹមជីវិត ។ ដូចនេះធ្វើឱ្យមានសំពាធកាន់តែខ្លាំងទៅលើធនធានជលផល ។ ផលត្រីដែលចាប់បានគឺផ្អែកទៅតាមរដូវ : ចាប់បានច្រើននៅពេលដែលទំហំទឹកតូច និង ខ្យល់តិច ហើយចាប់បានតិចនៅពេលដែលទឹកបាចសាចខ្លាំង និង លក្ខខ័ណ្ឌអាកាសធាតុមិនល្អនៅរដូវមូសុង ។

ការប្រែប្រួលនៅប្រាក់ចំណូលដែលបានមកពីការធ្វើនេសាទទៅតាមរដូវបាននាំទៅរកភាពងាយរងគ្រោះថ្នាក់ដល់សហគមន៍ដែលពឹងផ្អែកលើការនេសាទ ។ ដើម្បីកាត់បន្ថយនៅការជះឥទ្ធិពលតាមរដូវកាល ការសិក្សាសាកល្បងនៃការបំប៉នត្រីទីឡាព្យ៉ានៅក្នុងបែត្រូវបានធ្វើនៅសហគមន៍ក្នុងខេត្តភាគពាយ័ព្យ ។ ត្រីរស់ត្រូវបានគេចាប់ពីអាងហើយ ស្តុកនៅក្នុងបែដែលធ្វើពីសំភារៈរកបាននៅក្នុងស្រុកហើយមានតំលៃថោក ។ ចំណីត្រីត្រូវបានគេធ្វើពីកន្ទក់ ត្រី ឬ កាកសំណល់ត្រីដែលតែងតែរកបានដោយគ្មានបង់ថ្លៃ ។

## ការចូលរួម :

អត្ថបទនេះអធិប្បាយពីប្រជាជនដែលចូលរួមនៅក្នុងការពិសោធន៍ការបំប៉នត្រីនៅក្នុងបែដោយកសិករ និង បញ្ហាដែលពួកគេកំពុងជួបប្រទះ ។ លក្ខណៈ និង កំរិតនៃការចូលរួមគឺផ្អែកទៅលើកត្តាជាច្រើន ។ ប្រភេទសហគមន៍ និង យិនឌឺនៃ ការចូលរួមគឺជាកត្តាសំខាន់ដែលកំណត់ការចូលរួមរបស់ប្រជាជន ។

## <u>សហគមន៍កសិកម្ម</u> :

ចាប់ និង លក់ត្រីគឺជាការងាររបស់បុរស ។ កំរិតនៃការចូលរួមរបស់ស្ត្រីនៅក្នុងវិស័យជលផលគឺបានត្រឹមតែ សំអាត និង ជួសជុលមង ហើយជួនកាលកែច្នៃត្រីតែប៉ុណ្ណោះ។ ជាហេតុធ្វើឱ្យមានតែបុរសប៉ុណ្ណោះដែលចាប់អារម្មណ៏ ចូលរួមនៅក្នុងការសាកល្បងស្រាវជ្រាវនេះ។

**ការចូលរួមរបស់ស្ត្រី :** ទំនៀមទំលាប់ដែលទាក់ទងនឹងការនេសាទ ការខ្វះខាតធនធានសំខាន់ៗ គឺហាក់ដូច ជាបញ្ហាដែលរារាំងដល់ការចូលរួមរបស់ស្ត្រីនៅក្នុងការសាកល្បងក្នុងសហគមន៏កសិកម្ម។ ដោយសារតែស្ត្រីមិនចូលរួម នៅក្នុងការនេសាទ ការចូលរួមរបស់ពួកគេជួបនឹងបញ្ហាកង្វះខាតត្រីរស់ដើម្បីស្តុកនៅក្នុងបែ និង មិនអាចជិះទូកទៅ ដាក់ចំណីឱ្យត្រី។

**ការចូលរួមរបស់បុរស :** ការពិនិត្យពីការចិញ្ចឹមជីវិតបានបង្ហាញថា សកម្មភាពរកប្រាក់ចំណូលផ្សេងៗ ទៀតបានជះឥទ្ធិពលដល់ការចូលរួមរបស់បុរសក្នុងការចិញ្ចឹមត្រីនៅក្នុងបែ ។ ការចិញ្ចឹមត្រីក្នុងបែមិនត្រូវបានគេចាប់ អារម្មណ៏ទេនៅពេលដែលគេជាប់រវល់នឹងការងារធ្វើស្រែចំការផ្សេងទៀត។ នេះបញ្ជាក់ថា ការចិញ្ចឹមត្រីក្នុងបែគឺមាន អាទិភាពទាប ប៉ុន្តែវាអាចផ្លាស់ប្តូរក្នុងពេលអនាគត ។ ការធ្វើលំហាត់ចំណាត់ថ្នាក់បានបញ្ជាក់ថា ការពិបាករកត្រី ដើម្បីដាក់ចិញ្ចឹមគឺជាមូលហេតុដែលធ្វើឱ្យពួកគេឈប់ចិញ្ចឹម ។ អ្នកខ្លះនៅតស៊ូចិញ្ចឹម ហើយចុងក្រោយពួកគេអាច ប្រមូលផលបាន ។ បទពិសោធន៏ល្អៗរបស់ពួកគេ បានធ្វើឱ្យមានការចាប់អារម្មណ៏ជាថ្មីដល់កសិករដែលសំរេចចិត្តចង់ ចិញ្ចឹមត្រីក្នុងបែ ។ កសិករខ្លះបានពង្រីកការចិញ្ចឹមរបស់ខ្លួនពីបែ ១ ទៅបែ ៣ ។ កសិករទាំងនេះបានជ្រើសរើសការ ចិញ្ចឹមត្រីក្នុងបែតូចៗច្រើន ជៀសជាងការចិញ្ចឹមត្រីក្នុងបែធំមួយដែលជាយុទ្ធសាស្រ្តជៀសវាងការផ្សងគ្រោះថ្នាក់។

## <u>សហគមន៍នេសាទ</u> :

ក្នុងប្រទេសសិរីលង្កា មានគ្រួសារអ្នកនេសាទមកពីតំបន់ឆ្នេរជាច្រើនបានផ្លាស់ទីលំនៅមករស់នៅជុំវិញអាង ធំៗ ។ សហគមន៏ទាំងនេះមានទំនៀមទំលាប់ធ្វើនេសាទ ហើយគ្មានបទពិសោធន៏ធ្វើកសិកម្មទេ ។ ស្ត្រីនៅក្នុង សហគមន៏ទាំងនេះមានតួនាទីយ៉ាងសកម្មក្នុងការនេសាទ និង សកម្មភាពទាក់ទងផ្សេងៗទៀតបើប្រៀបធៀបទៅនឹង សហគមន៏កសិកម្ម ។ មានគំនិតសង្គមខ្លះដែលទាក់ទងនឹងតួនាទីរបស់យិនឌ័ក្នុងការនេសាទនៅក្នុងសហគមន៏ទាំងនេះ ដែគូអ្នកនេសាទខ្លះរួមមានប្តី និង ប្រពន្ធ ។ ប៉ុន្តែមានស្ត្រីច្រើនហាក់ដូចជានៅស្ទាក់ស្ទើរក្នុងការចែវទូកទៅនេសាទ ដោយគ្មានវត្តមានរបស់បុរសនោះ ។ នេះបង្ហាញថា ស្ត្រីនៅតែពឹងផ្អែកលើបុរសក្នុងការចូលរួមធ្វើនេសាទ។

**ការចូលរួមរបស់ស្ត្រី :** នៅពេលដែលគំនិតនៃការបំប៉នត្រីក្នុងបែត្រូវបានគេបំផុសនៅក្នុងសហគមន៍នេះ ស្ត្រីគឺជាអ្នកទីមួយដែលបានចូលរួមនៅក្នុងសកម្មភាពដាក់បែចិញ្ចឹមមុនបុរស ។ ថ្វីត្បិតតែស្ត្រីមានចំណាប់អារម្មណ៍ខ្ពស់ពួកគេមិនអាចចិញ្ចឹមត្រីដោយគ្មានបុរសបានទេ ពួកគេត្រូវការជំនួយពីបុរសដើម្បីចាប់ត្រីពីអាងមកស្តុក។ ដោយសារមូលហេតុនេះមានស្ត្រីក្រីក្រជាច្រើន ជាពិសេសស្ត្រីដែលជាមេគ្រួសារមិនអាចចិញ្ចឹមបាន ។ ស្ត្រីដែលមានប្តី ឬ មានបងប្អូនបុរសអាចបន្តការចិញ្ចឹមបាន ដោយសារពួកគេអាចរកត្រីពីការនេសាទរបស់បុរសដើម្បីស្តុកក្នុងបែ ។ មានស្ត្រីជាច្រើនបានរៀបរាប់ថា បងប្អូនរបស់ពួកគេមិនបានជួយចាប់ត្រីដើម្បីយកមកដាក់ក្នុងបែទេដោយសារគេជាប់រវល់ការងារជាអាទិភាពផ្សេងទៀត។

នៅពេលស្ត្រីដាក់ត្រីចិញ្ចឹមពួកគេមានការថែទាំល្អជាងបុរស។ ពួកគេមានសារៈធាតុធ្វើចំណី (កាកសំណល់កែច្នៃត្រី និង កាកសំណល់ផ្ទះបាយ) ហើយផ្តល់ចំណីទៀងទាត់។

**ការចូលរួមរបស់បុរស :** បុរសមិនសូវមានការចាប់អារម្មណ៍ក្នុងការចិញ្ចឹមត្រីក្នុងបែនៅក្នុងសហគមន៍នេះ គឺដោយសារពួកគេជាប់រវល់ក្នុងការនេសាទ ។ ការនេសាទនៅក្នុងសហគមន៍នេះចេះតែកើនឡើង ធ្វើឱ្យចំណូលចេះតែកើនឡើងដែរ ដូច្នេះពួកគេមិនចាំបាច់ទៅធ្វើអ្វីផ្សេងទៀតទេ ។ បុរសបានចាត់ចែងការងាររៀបចំ និង ដាក់ចំណីត្រីឱ្យទៅស្ត្រី និង កុមារ ចំណែកឯបុរសបន្តការងារនេសាទ និង សកម្មភាពផ្សេងទៀត។

## <u>ក្តីសង្ឃឹមក្នុងពេលអនាគត</u> :

ស្ថានភាពដែលបានរៀបរាប់ ឆ្លុះបញ្ចាំងនូវស្ថានភាពចូលរួមនាពេលបច្ចុប្បន្ន ក្នុងរយៈពេលពីរវដ្តនៃការស្រាវជ្រាវកន្លងមកនេះ ។ លទ្ធផលដែលបានមកពីសហគមន៍កសិកម្មគឺជាក្តីសង្ឃឹមមួយដោយសារកសិករជាច្រើនបានមកចូលរួមសាជាថ្មីជាមួយគំរោងនេះបញ្ជាក់ថា ពួកគេបានមើលឃើញពីផលប្រយោជន៍នៃការចិញ្ចឹមត្រីក្នុងបែ ។ ការធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាពនៃប្រព័ន្ធនេះអាចទាក់ទាញប្រជាជនកាន់តែច្រើនឡើងទទួលយកនូវបច្ចេកវិទ្យានេះ ។ សារៈសំខាន់នៃការចិញ្ចឹមជីវិតដោយមុខរបរផ្សេងៗគឺមានការយល់ដឹងច្រើននៅក្នុងសហគមន៍កសិកម្មជាងសហគមន៍នេសាទ ។ សក្តានុពលនៃការនេសាទផលស្តុកត្រីហួសហេតុនៅក្នុងអាងធំៗអាចបង្ខំឱ្យសហគមន៍នេសាទត្រូវពិចារណាលើការរកប្រភពប្រាក់ចំណូលពីមុខរបរផ្សេងៗ ។ ហេតុដូច្នេះហើយ ការចិញ្ចឹមត្រីក្នុងបែធុនតូច ជាមធ្យោបាយនៃការគ្រប់គ្រងការប្រែប្រួលប្រាក់ចំណូល អាចក្លាយជាកត្តាសំខាន់មួយដល់សហគមន៍ទាំងនេះក្នុងពេលអនាគត។

Lindsay J Pollock គឺជាបណ្ឌិតស្រាវជ្រាវ ហើយលោក David C Little គឺជាអ្នកបង្រៀនខាងការស្រាវជ្រាវជាមួយ （System Group） វិទ្យាស្ថានវារីវប្បកម្ម សាកលវិទ្យាល័យ ស្ទីលីង ប្រទេសស្កុដលែន, ចក្រភពអង់គ្លេស ។ យើងអាចទាក់ទងពួកគេបានតាមរយៈអ៊ីមែល ៖ l.j.pollock@stir.ac.uk និង d.c.little@stir.ac.uk.

# ធ្វើអន្តរកម្មជាមួយអ្នកជាប់ពាក់ព័ន្ធ និង អ្នកធ្វើគោលនយោបាយ

**ដោយ** To Phuc Tuong

## **ហេដ្ឋារចនាសម្ព័ន្ធ និង ការច្នៃប្រឌិត :**

ការកើនឡើងនូវតំរូវការស្រូវក្នុងទសវត្សរ៍ ៨០ និង ៩០ សំរាប់ប្រើប្រាស់ក្នុងស្រុក និង ធ្វើការនាំចេញបាន ជំរុញឱ្យរដ្ឋាភិបាលវៀតណាមធ្វើផែនការ និង វិនិយោគទៅលើការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធដើម្បីបង្កើនផលិតផល ស្រូវ ជាពិសេសនៅតំបន់ដីសណ្តទន្លេមេគង្គ ។ ចាប់ពីឆ្នាំ ១៩៩៣ ដល់ ២០០០ មានការសាងសង់ទំនប់ និង ទ្វារ បង្ហូរទឹកជាច្រើនតាមបណ្តោយឆ្នេរក្នុងខេត្ត សុងត្រាង និង បាក់លឿ ដើម្បីការពារផ្ទៃដីប្រមាណ ២០០.០០០ ហ.ត ពីការវាតទីនៃជាតិប្រៃ និង ដើម្បីធ្វើប្រពលវប្បកម្មនៃដំណាំស្រូវ ។ ប៉ុន្តែនៅចុងទសវត្សរ៍ទី ៩០ មុនពេលសាងសង់ ទ្វារទឹកចុងក្រោយនៃគំរោង Quan Lo-Phung Hiep វៀតណាមបាននាំស្រូវចេញក្រៅប្រទេស ៤ លានតោន ជា រៀងរាល់ឆ្នាំរួចទៅហើយ ហើយតំលៃស្រូវទីផ្សារក្នុងស្រុកមានការធ្លាក់ថ្លៃយ៉ាងខ្លាំង។

ក្នុងពេលជាមួយគ្នានេះដែរ ប្រពៃណីនៃការចិញ្ចឹមបង្គានៅភាគខាងលិចនៃតំបន់នេះ មានការច្នៃប្រឌិតជា ច្រើនដែលជួយបង្កើនផលិតភាពនៃស្រែបង្គា ។ ពួកគេលែងពឹងផ្អែកទាំងស្រុងទៅលើការផ្គត់ផ្គង់កូនបង្គាពីធម្មជាតិ (ដែលកាន់តែថយចុះ) ប៉ុន្តែឥឡូវនេះពួកគេអាចនាំចូលកូនបង្គាពីភាគកណ្តាលវៀតណាម ។ ពួកគេដឹងកាន់តែច្រើនពី របៀបត្រួតពិនិត្យគុណភាពទឹកនៅក្នុងស្រែរបស់ពួកគេ។ ជាមួយគ្នានេះដែរ ក្រោមការកែទំរង់សេដ្ឋកិច្ច បង្គាត្រូវបាន គេនាំចេញទៅទីផ្សារអន្តរជាតិដែលជាហេតុធ្វើឱ្យតំលៃលក់នៅកសិដ្ឋានមានការកើនឡើង។

## **គំរោងដោយមានការចូលរួម :**

គំរោង DFID-CRF " បង្កើនការកាត់បន្ថយភាពក្រីក្រ តាមរយៈការគ្រប់គ្រងធនធានឱ្យមាននិរន្តរភាព នៅតំបន់ឆ្នេរការពារពីការរាលដាលនៃជាតិប្រៃ ជាករណីសិក្សាមួយក្នុងប្រទេសវៀតណាម " ដែលត្រូវបានផ្តើមជា គំនិតឡើងនៅឆ្នាំ ១៩៩៩ ហើយត្រូវបានអនុវត្តនៅដើមឆ្នាំ ២០០០។ គំរោងបានប្រើយុទ្ធវិធីដោយមានការចូលរួមជា មួយអាជ្ញាធរក្នុងស្រុកដើម្បីកំណត់ពីឥទ្ធិពលនៃគំរោងការពារជាតិប្រៃលើបរិស្ថាន និង ជីវភាពរស់នៅរបស់ប្រជាជន ហើយរកនូវបច្ចេកវិទ្យាដែលអាចបង្កើនផលចំណេញ និង កាត់បន្ថយការជះឥទ្ធិពលអវិជ្ជមាននៃវិធានការការពារជាតិ ប្រៃលើគ្រួសារមានកសិដ្ឋានតូចតាច។

ចាប់ផ្តើមពីដំណាក់កាលដំបូងនៃគំរោងស្រាវជ្រាវ សមាជិកនៃក្រុមបានធ្វើការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរ ដែនដីដើម្បីពន្យល់ពីគោលបំណងនៃការសិក្សា ប្រមូលមតិរបស់ពួកគេ និង សហការក្នុងការប្រមូលទិន្នន័យ និង រាយ

ការណ៍ពីលទ្ធផលនៃការស្រាវជ្រាវ។ ការងារនេះត្រូវបានសំរបសំរួលដោយ "ផ្នែកសំរបសំរួលក្នុងស្រុក" ដឹកនាំដោយ អនុប្រធាននាយកដ្ឋានកសិកម្ម និង អភិវឌ្ឍន៍ជនបទដែលមានជំនួយការម្នាក់ជ្រើសរើសមកពីមជ្ឈមណ្ឌលសេវាផ្សព្វផ្សាយកសិកម្ម។

## ការចិញ្ចឹមជីវិត និង គោលនយោបាយ :

នៅពេលដែលទ្វារទឹកនៅចុងភាគខាងលិចនៃគំរោង Quan Lo-Phung Hiep ត្រូវបានដាក់ឱ្យដំណើរការនៅឆ្នាំ ២០០០ ការផ្គត់ផ្គង់ទឹកភ្លាវដល់កសិដ្ឋានចិញ្ចឹមបង្គាជាច្រើនត្រូវបានកាត់ផ្តាច់។ កសិករជាច្រើនបានបោះបង់ការចិញ្ចឹមបង្គាដែលជាហេតុធ្វើឱ្យពួកគេបាត់បង់ចំណូលជាច្រើន។ គំរោងបានអនុវត្តការសិក្សាពីការផ្លាស់ប្តូរការប្រើប្រាស់ដី និង សេដ្ឋកិច្ច-សង្គម ដើម្បីគណនាពីការជះឥទ្ធិពលនៃគំរោងការពារទឹក លើអ្នករកស៊ីចិញ្ចឹមបង្គា និងធ្វើស្រែទាំងគ្រួសារ អ្នកមាន អ្នកមធ្យម និង អ្នកក្រីក្រ។ គំរោងបានរកឃើញថា ក្រៅពី "អ្នកចំណេញ" (អ្នកស្រែនៅភាគខាងកើតនៃគំរោង) មាន "អ្នកខាត" ជាច្រើន (អ្នកចិញ្ចឹមបង្គានៅភាគខាងលិច កសិករក្រីក្រ និង គ្មានដីធ្លីជាច្រើនដែលជីវភាពរបស់ពួកគេពឹងផ្អែកទាំងស្រុងលើធនធានជលផល)។

ទិន្នន័យទាំងនេះ រួមផ្សំនឹងហេតុការណ៍នៅក្នុងខែកុម្ភៈ ២០០១ ដែលពេលនោះមាន "អ្នកខាត" ខ្លះបានបំផ្លាញរចនាសម្ព័ន្ធការពារជាតិប្រៃ ដែលផ្តល់ដល់រដ្ឋបាលក្នុងស្រុកនូវភ័ស្តុតាងបង្ហាញដល់រដ្ឋាភិបាលកណ្តាលឱ្យពិនិត្យឡើងវិញនូវទិសដៅនៃការអភិវឌ្ឍន៍ ដែលផ្តោតទៅលើការបង្កើនផលិតផលស្រូវ ។ ឥឡូវនេះរដ្ឋបាលក្នុងស្រុកត្រូវបានគេអនុញ្ញាតិឱ្យពិនិត្យមើលនូវការផ្លាស់ប្តូរការប្រើប្រាស់ដីធ្លីដែលអាចចិញ្ចឹមបង្គានៅភាគខាងលិចនៃខេត្ត ហើយទុកភាគខាងកើតដើម្បីធ្វើប្រពលវប្បកម្មដំណាំស្រូវ។

អ្នកធ្វើគោលនយោបាយ និង អ្នកធ្វើការសំរេចចិត្តត្រូវចូលរួមក្នុងការផ្លាស់ប្តូរគោលនយោបាយការប្រើប្រាស់ដី និង គ្រប់គ្រងគំរោងត្រួតពិនិត្យទឹកដើម្បីដោះស្រាយស្ថានភាពដែលកំពុងកើតឡើងនេះ។ អាជ្ញាធរស្រុក និង ខេត្តបាក់លឿ បានចូលរួមជាសមាជិកនៃក្រុម ក្នុងការបង្កើតផែនការតំបន់ប្រើប្រាស់ដី ដោយគិតទៅលើស្ថានភាពជាក់ស្តែង និង សេចក្តីត្រូវការរបស់កសិករ ពីគុណសម្បត្តិ និង គុណវិបត្តិ នៃគំរោង។ លទ្ធភាពនៃការអនុវត្តន៍គំរោងតំបន់ប្រើប្រាស់ដីគឺផ្អែកទៅលើការគ្រប់គ្រងទ្វារទឹកដែលអាចឱ្យអ្នកចិញ្ចឹមបង្គាមានទឹកភ្លាវ អ្នកស្រែមានទឹកសាបដើម្បីផលិតស្រូវច្រើនសារ ហើយកសិករនៅអន្តរតំបន់អាចចិញ្ចឹមបង្គានៅខែប្រាំង និង ធ្វើស្រែនៅខែវស្សា។ ក្រុមនៃគំរោងបានប្រើប្រាស់ប្រព័ន្ធពតិមានភូមិសាស្ត្រ (GIS) ដែលភ្ជាប់ទំនាក់ទំនងរវាងធារទឹក និង ក៏រិតអំបិលដើម្បីពិនិត្យមើលចលនានៃទឹកប្រៃ និង ទឹកសាបនៅតាមបណ្តោញប្រឡាយ។ លទ្ធផលនៃការសិក្សាត្រូវបានគេយកមកពិភាក្សាជាមួយអាជ្ញាធរស្រុក និង ខេត្តដើម្បីជ្រើសរើសផែនទីតំបន់ប្រើប្រាស់ដីដែលត្រូវបានយល់ព្រមដោយអាជ្ញាធរស្រុកផ្សេងៗ។

ក្រុមនៃគំរោងទទួលបាននូវទិន្នន័យ និង ការជួយគាំទ្រពីអ្នកធ្វើផែនការប្រើប្រាស់ដីធ្លី នៃវិទ្យាស្ថានជាតិផែនការកសិកម្ម និង គំរោងដែលមានមូលដ្ឋាននៅទីក្រុង ហូជីមិញ។

**<u>សហប្រតិបត្តិការ និង ការអនុវត្តន៍</u> :**

ដោយប្រើម៉ូដែលធារទឹក ក្រុមនៃគំរោងសហការជាមួយនឹងក្រុមហ៊ុនដែលទទួលខុសត្រូវអនុវត្តគំរោងត្រួតពិនិត្យទឹកកំណត់ថា តើត្រូវបិទបើកទ្វារទឹកយ៉ាងដូចម្តេចដើម្បីឱ្យទឹកប្រៃហូរទៅភាគខាងលិចដើម្បីចិញ្ចឹមបង្គានៅរដូវប្រាំង និង ការពារកុំឱ្យទឹកប្រៃជ្រៀតទៅភាគខាងកើតដែលអាចដាំស្រូវ ២ ទៅ ៣ ដងក្នុងមួយឆ្នាំ ។ ការបិទបើកទ្វារទឹកដែលគេត្រូវការគឺដូចការអនុវត្តន៍នៅឆ្នាំ ២០០១ ។ កាលវិភាគនៃការបិទបើក គឺកែសំរួលដោយប្រើទិន្នន័យពីបណ្តាញត្រួតពិនិត្យគុណភាពទឹកដែលគំរោងបានជួយដល់រដ្ឋបាលក្នុងស្រុក ក្នុងការបង្កើតទូទាំងខេត្តហើយដែលអនុវត្តដោយបុគ្គលិកស្រុក។ ការផ្ញើអ៊ីមែលទៅវិញទៅមករវាង " ផ្នែកសំរបសំរួល " និង សមាជិកក្រុមនៅក្នុងនឹងក្រៅប្រទេសវៀតណាម បានដើរតួនាទីសំខាន់ក្នុងដំណើរការធ្វើការសំរេចចិត្ត។ ដោយទទួលបាននូវលទ្ធផលគួរឱ្យពេញចិត្តនៅក្នុងឆ្នាំ ២០០១ អាជ្ញាធរក្នុងស្រុកសំរេចចិត្តបន្តប្រើប្រាស់ (Simulation model) ជាវិធានសំរាប់ធ្វើការសំរេចចិត្តក្នុងការអនុវត្តន៍ការគ្រប់គ្រងទឹកនៅក្នុងឆ្នាំ ២០០២ ។

សំរាប់អ្វីដែលគំរោងនៅសេសសល់ដល់ខែ មេសា ឆ្នាំ ២០០៣ ក្រុមស្រាវជ្រាវនឹងបន្តត្រួតពិនិត្យ និង វាយតំលៃពីឥទ្ធិពលនៃការផ្លាស់ប្តូរនេះ លើការចិញ្ចឹមជីវិតរបស់ប្រជាជននៅជនបទ ដោយផ្តោតជាសំខាន់លើកសិករក្រីក្រ និង គុណភាពបរិស្ថាននៃតំបន់សិក្សា ។ គេសង្ឃឹមថាបទពិសោធន៍នេះអាចផ្សព្វផ្សាយទៅតំបន់ឆ្នេរផ្សេងៗទៀត។

To Phuc Tuong គឺជាវិស្វករគ្រប់គ្រងទឹកដែលធ្វើការជាមួយ វិទ្យាស្ថានស្រាវជ្រាវដំណាំស្រូវអន្តរជាតិ International Rice Research Institute (IRRI), Los Banos, Philippines ហើយអាចទាក់ទងតាមរយះ អ៊ីមែល T.Tuong@cgiar.org

គំរោងត្រូវបានអនុវត្តដោយវិទ្យាស្ថានស្រាវជ្រាវដំណាំស្រូវអន្តរជាតិ ( IRRI ) សហការជាមួយសកលវិទ្យាល័យ University of Newcastle upon Tyne មជ្ឈមណ្ឌលអន្តរជាតិសំរាប់ការគ្រប់គ្រងធនធានវារិជាតមានជីវិត (ICLARM) សកលវិទ្យាល័យ កាន់ធឺ នាយកដ្ឋានកសិកម្ម និង អភិវឌ្ឍន៍ជនបទនៃខេត្តបាក់លឿ អនុវិទ្យាស្ថានផែនការធនធានទឹក និង មជ្ឈមណ្ឌលផែនទីធនធានចំរុះ។

## តួនាទីនៃចំណេះដឹងខាងជីវជាតិក្នុងការជួយសំរួលបញ្ហាលំបាក
## នៅក្នុងតំបន់អាស៊ីប៉ាស៊ីភិច

**ដោយ** Georgina Cairns

### ជីវជាតិល្អសំរាប់ទាំងអស់គ្នា :

ចំណីអាហារដែលយើងបរិភោគមានតួនាទីច្រើនវាជាប្រភព និង និមិត្តរូបនៃសេចក្ដីរីករាយ ពិធីបុណ្យផ្សេងៗ និង មិត្តភាព ។ វាជាប្រភពជីវជាតិសំខាន់ៗ និង ពេលខ្លះវាជាការគំរាមកំហែងដល់សុខភាពយើង ដោយសារតែ អតិសុខុមជីវសាស្ត្រ សារធាតុប្រឆាំងនឹងជីវជាតិ និង ការប្រើប្រាស់ជាតិគីមី ។ ដើម្បីធ្វើឱ្យបាននូវចំណីអាហារល្អ វាផ្អែកលើការរកបាននូវម្ហូបគ្រប់គ្រាន់ដែលមានជីវជាតិល្អ ហើយមានសុវត្ថិភាពក្នុងការបរិភោគ ។ វិទ្យាសាស្ត្រខាង ចំណីអាហារ និង វេជ្ជសាស្ត្រយល់ដឹងយ៉ាងច្រើនពីធាតុដែលមាននៅក្នុងចំណីអាហារដែលល្អ។ របៀបប្រើចំណេះដឹង ដើម្បីជួយ និង ជំរុញឱ្យពួកគេជ្រើសរើសចំណីអាហារដែលល្អ គឺមិនសូវមានការយល់ដឹងទេ ប៉ុន្តែកាន់តែមានការចាប់ អារម្មណ៍ដល់ភាគីជាច្រើនដែលទាក់ទងនឹង ចំណីអាហារ និង សុខភាព។

សន្និសិទអន្តរជាតិស្តីពី ជីវជាតិ នៅឆ្នាំ ១៩៩២ បានទទួលស្គាល់ពីតួនាទីរបស់ចំណីអាហារនៅក្នុងជីវិតរបស់ យើង ហើយបានដាក់ចេញនៅក្នុង " សេចក្តីថ្លែងការណ៍ និង ផែនការសកម្មភាព " ពីទិសដៅគឺ " ជីវជាតិល្អសំរាប់ យើងទាំងអស់គ្នា " ត្រូវតែចែករំលែកនូវការទទួលខុសត្រូវ ។ ដើម្បីសំរេចបាននូវទិសដៅនេះចាំបាច់ត្រូវមានការជួយ ឧបត្ថម្ភ និង ការប្តេជ្ញាចិត្តពីគ្រប់ផ្នែកទាំងអស់នៃសង្គម : កសិកម្ម សុខាភិបាល និង អប់រំ ថវិកា និង ផែនការ ឧស្សាហកម្ម ចំណីអាហារ អ្នកបរិភោគ និង អង្គការមិនមែនរដ្ឋាភិបាល ។

ទ្វីបអាស៊ីជួបប្រទះនឹងបញ្ហាជីវជាតិពីរដែលខុសពីតំបន់ផ្សេងៗទៀតនៃពិភពលោកគឺ ខុសគ្នាលើអាទិភាពខាង សុខាភិបាល និង ទំនាក់ទំនង ការហូបចំណីអាហារដែលគ្មានជីវជាតិគ្រប់គ្រាន់ និង ការហូបចំណីអាហារលើសកំរិត។

### ការហូបចំណីអាហារដែលគ្មានជីវជាតិគ្រប់គ្រាន់ :

មានសមាមាត្រប្រជាជននៅក្នុងទ្វីបអាស៊ីជាច្រើន ហូបចំណីអាហារដែលគ្មានជីវជាតិគ្រប់គ្រាន់ ។ ថ្វីត្បិតតែ គេជឿថាសមាមាត្រនេះមានការថយចុះ កង្វះជីវជាតិគឺជាបញ្ហាសំខាន់មួយនៅក្នុងបណ្តាប្រទេសជាច្រើន ហើយភាគ ច្រើននៅតំបន់ជនបទ ។ មានមូលហេតុជាច្រើនចំពោះបញ្ហានេះ គ្មានមធ្យោបាយជ្រើសរើស និង មិនអាចរកបាននូវ ផលិតផលចំណីអាហារក្នុងស្រុក និង បំរែបំរួលការរកបានទៅតាមរដូវកាល។

អ្នកឃ្លាន (កង្វះជាតិប្រូតេអ៊ីនដែលជាប្រភពនៃថាមពល) គឺជាឧទាហរណ៍ជាក់ស្តែងមួយនៃកង្វះជីវជាតិ ។ ប៉ុន្តែកង្វះមីក្រូជីវជាតិ (ជាពិសេស ជាតិដែក វីតាមីន A ស័ង្កសី អ៊ីយ៉ូត និង កាល់ស្យូម) ប្រហែលជាងាយស្រួលដឹង ប៉ុន្តែប្រហែលជាមូលហេតុចំបងនៃបញ្ហាសុខភាពនៅអាស៊ី ។ កង្វះជីវជាតិត្រូវបានគេទទួលស្គាល់ថា វាជាលទ្ធផលដោយផ្ទាល់ និង ប៉ះពាល់ដល់ការអភិវឌ្ឍន៍ជាតិ។ កង្វះមីក្រូជីវជាតិគឺមានជាប់ទាក់ទងដល់ការអភិវឌ្ឍន៍ខាងគំនិតបញ្ញា ងាយឆ្លងជំងឺកូន និង អត្រាក្មេងស្លាប់ខ្ពស់។

ក្មេង និង ស្ត្រីដែលមានអាយុនៅមានកូនគឺងាយទទួលរងគ្រោះថ្នាក់ដោយសារតែតំរូវការជីវជាតិកើនឡើង ហើយពេលខ្លះដោយសារតែរបៀបរៀបចំចំណីអាហារតាមបែបបុរាណធ្វើឱ្យក្មេង និង ស្ត្រីទទួលនូវចំណីអាហារដែលមានគុណភាពមិនល្អក្នុងគ្រួសារ (ឧទាហរណ៍. មានមាឌធំ មានជីវជាតិទាប )។ ភាពងាយទទួលរងគ្រោះថ្នាក់នៃក្រុមមនុស្សទាំងនេះ គឺដោយសារតែចំណីអាហារហូបមិនបានគ្រប់គ្រាន់ហើយវាទាក់ទងទៅនឹងកំរិតយល់ដឹងទាប ក្នុងចំណោមស្ត្រីកូនកើតមកមានទំងន់ស្រាល ហើយមិនមានសមាមាត្រនៃទំងន់ និង អាយុនៃកូនក្មេងនោះទេ ទាំងនេះបញ្ជាក់ថា ការផ្តោតការយកចិត្តទុកដាក់ទៅលើក្មេង និង ស្ត្រីគឺមានប្រសិទ្ធភាពបំផុត។ យុទ្ធសាស្ត្រប្រឆាំងទល់នឹងកង្វះជីវជាតិអាចរួមបញ្ចូលគំរោងជួយផ្តល់ចំណីអាហារ និង ជួយទំនុកបំរុង ការជួយអន្តរាគមន៍ដល់កសិ-សង្គម និងគំរោងអប់រំ។

## ការហូបចំណីអាហារលើសកំរិត :

ការហូបចំណីអាហារលើសពីសេចក្តីត្រូវការនៃថាមពលសរុប(កាឡូរី)ខ្លាញ់ដែលរលាយ និងធាតុកាបូអ៊ីដ្រាតរួមផ្សំ និង ការមិនធ្វើសកម្មភាពកាយវិការធ្វើឱ្យដុះក្បាលពោះ រួមនឹងជំងឺផ្សេងៗទៀតដូចជា ជំងឺទឹកនោមផ្អែម ជំងឺឆ្អឹង ជំងឺសរសៃឈាមបេះដូង និង អាចមានជំងឺមហារីក។ ហេតុការណ៍បែបនេះគេឱ្យឈ្មោះថា ជំងឺនៃរបៀបរស់នៅ[៧] (Lifestyle disease) ដែលកំពុងមានការកើនឡើងកាន់តែច្រើននៅបណ្តាប្រទេសអាស៊ី ។ ជំងឺបែបនេះ គឺវាទាក់ទងនឹងតែការកើនឡើងនូវភាពស្តុកស្តម្ភនៃប្រជាជន ។ ប៉ុន្តែវាអាចយល់ច្រលំនិយាយថា ការមានបានគឺជាមូលហេតុនោះ។ ជំងឺទាំងនេះវាប៉ះពាល់ទាំងអ្នកមានបំផុត និងអ្នកក្របំផុត ។ វាជាការប្រសើរបើសិនជាយើងពិនិត្យមើលទៅលើទំនាក់ទំនងរវាងកំរិតនៃសកម្មភាពដោយកំលាំងកាយ និង ការកើនឡើងនូវជំងឺនៃរបៀបរស់នៅ ។ ការអភិវឌ្ឍន៍ឧស្សាហកម្ម និង ចរាចរប្រជាជនពីជនបទមកទីក្រុងគឺធ្វើឱ្យមានការថយចុះនូវកំរិតនៃសកម្មភាពដោយកំលាំងកាយ។

មានអ្នកដែលធ្លាប់ធ្វើការដោយកំលាំងកាយជាច្រើន ដូចជា ក្នុងវិស័យកសិកម្ម ឥឡូវនេះផ្លាស់មកធ្វើការនៅមួយកន្លែង។ អ្នកដែលធ្លាប់ធ្វើការដោយកំលាំងកាយធ្ងន់ មានការពិបាករកចំណីអាហារឱ្យគ្រប់គ្រាន់ឱ្យស្របទៅ

[៧] ជាទំនោរនៅក្នុងសង្គមដែលមនុស្សចូលចិត្តបរិភោគអ្វីដែលលើសពីសេចក្តីត្រូវការរបស់ខ្លួន

នឹងតំរូវការថាមពលរបស់គេ ជាពិសេសអ្នកដែលមានប្រាក់ចំណូលទាប ។ អ្នកដែលធ្វើការនៅមួយកន្លែងមានការពិបាក នឹងដាក់កំហិតចំណីអាហារ ដើម្បីឱ្យស្របទៅនឹងកំរិតថាមពលដែលប្រើប្រាស់ ។ ជាលទ្ធផលគឺមានការកើនឡើងនៅទំងន់ខ្លួន ដោយសារតែថាមពលដែលលើសត្រូវបានប្តូរមកជាខ្លាញ់នៅក្នុងខ្លួន ។ ការលើសទំងន់គឺមានការជាប់ទាក់ទងយ៉ាងជិតស្និទ្ធជាមួយជំងឺរបៀបរស់នៅ ហើយមានពេលខ្លះ សូម្បីតែចុះទំងន់ល្មមអាចកាត់បន្ថយនូវរោគសញ្ញានៃជំងឺ។ មានភ័ស្តុតាងកាន់តែច្រើនឡើងដែលថា កំរិតនៃការធ្វើពលកម្មតិច អាចជាកត្តាសំខាន់ និង មានគ្រោះថ្នាក់ សូម្បីតែអ្នកដែលមិនលើសទំងន់ក៏ដោយ ។

## ពីគោលការណ៍ណែនាំពីជីវជាតិ ទៅ ការទំនាក់ទំនង និង ការអប់រំពីជីវជាតិ :

យុទ្ធវិធីដោះស្រាយនូវកង្វះជីវជាតិ និង ការហូបចំណីអាហារលើសកំរិត បានប្តូរពីការផ្តល់នូវពត៌មានវិទ្យាសាស្រ្ត ទាក់ទងនឹងចំណីអាហារ មកជាការផ្តល់ដំបូន្មានដោយផ្អែកលើការយល់ដឹងពីបញ្ហាដែលជាប់ទាក់ទងការជំរុញ និង ចំណេះដឹងដែលមាន ។ ឧទាហរណ៏ . គោលការណ៏ណែនាំពីជីវជាតិបង្កើននូវការឆ្លុះបញ្ចាំងពី :

- ចំណីអាហារដែលមាននៅក្នុងស្រុក (រួមទាំងតំលៃ ភាពងាយស្រួល និង ការរកបានទៅតាមរដូវ)
- របៀបរស់នៅ ( ឧទា. តើចំណាយពេលប៉ុន្មានដើម្បីរក ឬក៏ទិញ រៀបចំ ចំណីអាហារ និង ហូប )
- សារៈសំខាន់នៃចំណីអាហារ ជាប្រភពនៃការសប្បាយ (រសជាតិ និង ទំលាប់គឺជាកត្តាដែលមានឥទ្ធិពលបំផុតដល់ការជ្រើសរើសចំណីអាហារ)
- តួនាទីនៃចំណីអាហារក្នុងវប្បធមិ (មានពិធីបុណ្យប្រពៃណីជាច្រើន ដូចជា ពិធីជប់លៀង ឬ បុណ្យផ្សេងៗ ការជ្រើសរើសចំណីអាហារគឺកំណត់ដោយរបៀបរបបបុរាណ ) ។

ពត៌មានថ្មីៗពីសុខភាព និង ការជ្រើសរើសចំណីអាហារ ត្រូវបង្ហាញនូវភាពដែលគួរឱ្យជឿជាក់បាន ។ ការបង្ហាញពីផលប្រយោជន៍ ដោយតំលៃដែលអាចទទួលយកបាន ( ឧទា. ចរិកា សង្គម ភាពសមស្រប ) ចាំបាច់ត្រូវការពត៌មានថ្មីដើម្បីប្រើប្រាស់នៅពេលអនាគត និង ការជ្រើសរើសរបៀបរស់នៅ ។ ការប្រើប្រាស់ម៉ូដែល និង យុទ្ធសាស្រ្តដោយផ្អែកទៅលើការផ្លាស់ប្តូរបន្តិចម្តងៗអាចជួយដល់ការកសាងភាពជឿជាក់ ។

ពាក្យដែលល្អសំរាប់ប្រើក្នុងន័យពីការអប់រំពីជីវជាតិគឺ " ការទំនាក់ទំនងពីជីវជាតិ " ។ វាឆ្លុះបញ្ចាំងពីការយកចិត្តទុកដាក់ទៅលើសេចក្តីត្រូវការដើម្បីធ្វើអន្តរាគមន៍ ទាំងលើរបៀបរស់នៅ និង ផ្អែកទៅលើការរកឃើញនៃវិទ្យាសាស្រ្តថ្មីៗ ។

Geogina Cairns គឺជានាយកប្រតិបត្តិនៃ មជ្ឈមណ្ឌលពត៌មានចំណីអាហារ (AFIC) អាស៊ាន ហើយអាចទាក់ទង តាមរយៈអ៊ីមែល info@afic.org ។

ការងាររបស់ AFIC គឺផ្តល់ពត៌មានវិទ្យាសាស្ត្រពីចំណីអាហារ និង ជីវជាតិ នៅអាស៊ីដល់អ្នកឯកទេសខាងសុខភាព ភ្នាក់ងាររដ្ឋាភិបាល ឧស្សាហកម្មចំណីអាហារ និង បណ្តាញពត៌មាន ។ បើចង់ដឹងពត៌មានបន្ថែមសូមមើល Website: www.afic.org ។

# ពត៌មានពីទស្សនាវដ្ដីរបស់ STREAM

**បោះពុម្ពដោយ** : STREAM- Support to Regional Aquatic Resources Management
Network of Aquaculture Centres in Asia-Pacific (NACA) Secretariat
Suraswadi Building
Department of Fisheries Compound
Kasetsart University Campus
Ladyao, Jatujak, Bangkok 10903
Thailand

**ក្រុមអ្នកបោះពុម្ពផ្សាយ** :

Graham Haylor, នាយកនៃគំរោង STREAM

Le Thanh Luu, អ្នកសំរបសំរួលជាតិនៃគំរោង STREAMនៅវៀតណាម

William Savage, អ្នកជំនាញការខាងទំនាក់ទំនងនៃគំរោង STREAM

Thay Somony, អ្នកសំរបសំរួលជាតិនៃគំរោង STREAMនៅកម្ពុជា

**គោលបំណង** :

ទស្សនាវដ្ដីរបស់ STREAM បោះពុម្ពរៀងរាល់ត្រីមាសដើម្បីលើកកំពស់ការចូលរួម ទំនាក់ទំនង និង គោលនយោបាយដែលជួយដល់ជីវភាពរស់នៅអ្នកប្រើប្រាស់ធនធានវារិជាតក្រីក្រក្នុងតំបន់អាស៊ីប៉ាស៊ីភិច និង កសាង ទំនាក់ទំនងក្នុងវិស័យគ្រប់គ្រងធនធានវារិជាត និង ផ្នែកផ្សេងទៀតនៅក្នុងតំបន់ ។ ទស្សនាវដ្ដីរបស់ STREAM មានអត្ថបទដែលទាក់ទងនឹងប្រជាជនដែលការចិញ្ចឹមជីវិតរបស់ពួកគេពឹងផ្អែកលើធនធានជលផល ជាពិសេសប្រជាជន ដែលមានធនធានតិចតួច អ្នកអនុវត្ត រដ្ឋាភិបាល មិនមែនរដ្ឋាភិបាល និង អន្តរជាតិ ដែលធ្វើការជាមួយពួកគេក្នុង សហគមន៏។ បញ្ហាមានដូចជា : ការរៀនសូត្រ ការគ្រប់គ្រងជំលោះ បច្ចេកវិទ្យាទំនាក់ទំនង និង ពត៌មាន ការគ្រប់ គ្រងធនធានវារិជាត ច្បាប់ ការចិញ្ចឹមជីវិត យិនឌ័ ការចូលរួម អ្នកជាប់ពាក់ពន្ធ័ គោលនយោបាយ និង ទំនាក់ ទំនង ។

គោលបំណងសំខាន់មួយផ្សេងទៀតរបស់ទស្សនាវដ្ដី STREAM គឺផ្ដល់ឱកាសឱ្យបញ្ចេញសំលេងដែលកំរ មានដើម្បីឱ្យគេបានឮ និង មានតំណាងនៅក្នុងវិជ្ជាជីវបោះពុម្ពដែលមានបន្ថិចបន្តួចនៅក្នុងស្ថាប័នរៀនសូត្រ។ មាតិកា ក្នុងទស្សនាវដ្ដី មិនត្រូវយកទៅដើម្បីបញ្ជាក់ពីទស្សនៈនៃអង្គការ ឬ ភ្នាក់ងារណាមួយទេ ប៉ុន្តែវាគ្រាន់តែជាគំនិតនៃ មនុស្សម្នាក់ៗដោយផ្អែកលើបទពិសោធន៏របស់ពួកគេ ។ អ្នកនិពន្ធទទួលខុសត្រូវលើមាតិកាអត្ថបទរបស់ពួកគេ ហើយ STREAM ទទួលខុសត្រូវលើភាពលំអៀង និង លើសលួសផ្សេងៗ ។

## ការចែកចាយ :

ទស្សនាវដ្ដីរបស់ STREAM អាចរកបានជា ៣ ទំរង់ :

- ជាទំរង់អេឡិចត្រូនិចដែលត្រូវបានបោះពុម្ព និង ចែកចាយដោយ មណ្ឌលទំនាក់ទំនង STREAM
- ជាទំរង់ដែលអាចរកបាន ហើយទាញមកពី Website របស់ STREAM គឺ www.streaminitiative.org
- ជាឯកសារបោះពុម្ពដែលចែកចាយដោយ លេខាធិការដ្ឋាននៃ បណ្ដាញនៃមជ្ឈមណ្ឌលវារីវប្បកម្ម ក្នុងតំបន់អាស៊ីប៉ាស៊ីភិច

## ការចូលរួមចំណែក :

ទស្សនាវដ្ដីរបស់ STREAM លើកទឹកចិត្តដល់ការចូលរួមចំណែកជាអត្ថបទដែលទាក់ទងនឹងអ្នកប្រើប្រាស់ធនធានវារីជាត និង មនុស្សដែលធ្វើការជាមួយពួកគេ ។ ទស្សនាវដ្ដីរបស់ STREAM ក៏ជួយដល់សហការីដែលធ្វើការនៅថ្នាក់សហគមន៍ដើម្បីឱ្យចងក្រងឯកសារពីបទពិសោធន៍របស់ពួកគេនៅក្នុងទំព័រទាំងនេះ ។

អត្ថបទគួរសរសេរជាភាសាអង់គ្លេសដែលងាយយល់ ហើយមិនឱ្យលើសពី ១000 ពាក្យ ( ប្រហែល ២ ទំព័រ A4 )

អ្នកអាចផ្ដល់ជាអត្ថបទផ្សេងៗទៅឱ្យលោក William Savage អ្នកបោះពុម្ពផ្សាយ ទស្សនាវដ្ដីរបស់ STREAM តាមរយៈ savage@loxinfo.co.th. ។

ពតិមានបន្ថែមសូមទាក់ទងលោក Graham Haylor នាយកនៃគំរោង STREAM តាមរយៈអ៊ីមែល ghalor@loxinfo.co.th ។

# ពត៌មានពី STREAM

STREAM (ជួយគាំទ្រការគ្រប់គ្រងធនធានក្នុងទឹកក្នុងតំបន់) ជាគំរោងមួយដែលគ្រោងឡើងក្នុងរយៈពេល ពេល៥ឆ្នាំនៃកម្មវិធីការងាររបស់ NACA (បណ្តាញនៃមជ្ឈមណ្ឌលវារីវប្បកម្មក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិច) ។ គំរោងមានទិសដៅជួយដល់ទីភ្នាក់ងារ និង ស្ថាប័នផ្សេងៗឱ្យ :

- ប្រើប្រាស់ពតិមានដែលមានស្រាប់ឱ្យកាន់តែមានប្រសិទ្ធិភាព
- យល់ឱ្យកាន់តែច្បាស់ថែមទៀតពីជីវភាពរបស់ប្រជាជនក្រីក្រ
- អាចឱ្យប្រជាជនក្រីក្រ ប្រើប្រាស់ឥទ្ធិពលរបស់ខ្លួនលើគោលនយោបាយ និង ដំណើរការដែលជះឥទ្ធិពលលើជីវិតរបស់ពួកគេ ។

គំរោងនឹងធ្វើការងារនេះតាមរយៈការជួយអភិវឌ្ឍន៍គោលនយោបាយ និង ដំណើរការសំរបសំរួលស្ថាប័ន និង ការកសាងសមត្ថភាពដើម្បី :

- រកឱ្យឃើញនូវបញ្ហានៃការគ្រប់គ្រងធនធានក្នុងទឹកដែលជះឥទ្ធិពលទៅលើ ជីវភាពអ្នកក្រីក្រ
- ពិនិត្យ និង វាយតំលៃលើយុទ្ធវិធីគ្រប់គ្រងផ្សេងៗគ្នា
- ផ្សព្វផ្សាយពតិមាន
- ធ្វើបណ្តាញនៅក្នុង រវាងវិស័យ និង រវាងប្រទេស

គំរោងគឺផ្អែកលើភាពជាដៃគូរដែលជាប់ទាក់ទងចាប់តាំងពីការកកើតនូវការរួបរួមជាដៃគូ (DFID, VSO, FAO) ដែលជួយដល់ (NACA) ។ គំរោងនឹងទទួលយកនូវយុទ្ធវិធីសមស្របមួយដើម្បីសំរេចឱ្យបាននូវទំនាក់ទំនងរវាងអ្នកចូលរួមទាំងអស់ដែលជាប់ទាក់ទិននឹងការគ្រប់គ្រងធនធានក្នុងទឹក និង ជួយពួកគេឱ្យរួមចំណែកក្នុងការរៀបចំអនុវត្តន៍ និង ការគ្រប់គ្រងគំរោង ។

ការធ្វើការងាររបស់ដៃគូត្រូវបានសំរបសំរួល នៅក្នុងប្រទេសនិមួយៗតាមរយៈក្រុមសំរបសំរួលជាតិ ដែលរួមមាន : អ្នកសំរបសំរួលជាតិ( មន្ត្រីជាន់ខ្ពស់ដោយមានការយល់ព្រមជាមួយរដ្ឋាភិបាល) និង អ្នកគ្រប់គ្រងមណ្ឌលទំនាក់ទំនង (ជាមន្ត្រីដែលធ្វើការពេញម៉ោងហើយជួយឧបត្ថម្ភក្នុងរយៈពេល២ ឆ្នាំដំបូង ដោយ STREAM) ហើយភ្ជាប់ទំនាក់ទំនងជាមួយអ្នកជាប់ពាក់ព័ន្ធផ្សេងៗ ។ អ្នកគ្រប់គ្រងមណ្ឌលទំនាក់ទំនងត្រូវបានគេផ្តល់ឱ្យនូវ Hardware( មានដូចជា កំព្យូទ័រ ម៉ាស៊ីនស្កេន...) Software (កម្មវិធីកំព្យូទ័រ ដូចជា word, excel..) បំពាក់បំប៉ន ការជួយឧបត្ថម្ភដល់បច្ចេកវិទ្យាពតិមាន បណ្តាញ និង ធនធានមនុស្ស ហើយភ្ជាប់ជាមួយនឹងអ្នកជាប់ពាក់ព័ន្ធតាមរយៈ Internet ។

ការសំរបសំរួលជាតិ គឺអនុវត្តទៅតាមអត្ថបទយុទ្ធសាស្ត្រនៃប្រទេស (CSP) ដោយមានការពិនិត្យឡើងវិញជារៀងរាល់ឆ្នាំ ហើយធ្វើឡើងដោយអ្នកសំរបសំរួល និង អ្នកគ្រប់គ្រងមណ្ឌលទំនាក់ទំនង ដោយមានការពិគ្រោះយោបល់ជាមួយអ្នកជាប់ពាក់ព័ន្ធ ។ CSP រកឱ្យឃើញនូវបញ្ហាផ្តោតលើទំនាក់ទំនងក្នុងតំបន់ ធ្វើសំណើ និង ធ្វើអាទិភាពសកម្មភាពសំខាន់ និង ស្វែងរកថវិកាសំរាប់អនុវត្តសកម្មភាពនេះពី STREAM និង ពីកន្លែងផ្សេងៗទៀត (ដោយមានការជួយជ្រោមជ្រែងពី STREAM ) ។

ការិយាល័យតំបន់របស់ STREAM (នៅលេខាធិការ NACA ទីក្រុងបាងកក) ដឹកនាំគំរោង ផ្តល់នូវតួនាទីសំរបសំរួលក្នុងតំបន់ និង មូលនិធិ និង គ្រប់គ្រងបញ្ហាដែលទាក់ទងនឹងការចិញ្ចឹមជីវិត ការអភិវឌ្ឍន៍គោលនយោបាយ ទំនាក់ទំនង និង បញ្ហាពិសេសផ្សេងៗទៀត ។

ការប្រតិបត្តិរបស់ STREAM គឺជាដំណើរការដដែលៗមួយដែលធ្វើសាកល្បង នៅឆ្នាំទីមួយនៅកម្ពុជា និង វៀតណាមដែលជាកន្លែងមានឱកាសដើម្បីដោះស្រាយនូវភាពក្រីក្រ និង លើកកំពស់អភិបាលកិច្ចល្អ STREAM មានគំរោងពង្រីកទៅបណ្តាប្រទេសផ្សេងៗទៀតនៅពេលទទួលបានបទពិសោធន៍ មេរៀនត្រូវបានរៀន ការជះឥទ្ធិពលត្រូវបានដឹង ហើយថវិកាបន្ថែមត្រូវបានធានា ។ យុទ្ធសាស្ត្រទំនាក់ទំនងរបស់ STREAM គឺមានទិសដៅជួយបង្កើនឥទ្ធិពលដោយធានាថាចំណេះដឹងដែលមានស្រាប់នៅក្នុងតំបន់ និង ជំនាញការបានជា ពតិមានដល់ដំណើរការផ្លាស់ប្តូរនៅក្នុងតំបន់ ហើយបទពិសោធន៍ត្រូវបានចែកចាយទូទាំងតំបន់អាស៊ីប៉ាស៊ីភិច ។ ទស្សនាវដ្តីរបស់ STREAM រួមជាមួយវេទិកាពិភាក្សាដែលមាននៅលើ Website គឺជាផ្នែកនៃយុទ្ធសាស្ត្រនេះ ។

អាស័យដ្ឋានទំនាក់ទំនងៈ

STREAM Cambodia Communications Hub
Sem Viryak, Manager
<cfdo@camnet.com.kh>

STREAM Vietnam Communications Hub
Tran Ngoc Mai, Manager (Temporary)
<STREAMSAPA@vnn.hn.vn>